**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥០២ ប្រក កសក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់គំរូ ទម្រង់និងបែបបទនៃវិញ្ញាបនបត្រសុខភាព សម្រាប់បញ្ជាក់គុណភាពផល ផលិតផលជលផល

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

1

- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ ៣៨៦ ប្រក.កសក.ប ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពរដ្ឋបាលជលផល
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

## សម្រេច

### ប្រការ ១ .-

ប្រកាសនេះមានគោលបំណង ក្នុងការកំណត់នូវ គំរូ ទម្រង់ និងបែបបទនៃវិញ្ញាបនបត្រសុខភាពសម្រាប់បញ្ជាក់គុណភាពផល ផលិតផលជលផល ក្នុងការជំរុញការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណភាពនិងសុវត្ថិភាព ដើម្បីការពារសុខភាពសាធារណៈនិងលើកកម្ពស់ទីផ្សារនិងភាពប្រកួតប្រជែងក្នុងការនាំចេញផល ផលិតផលជលផល របស់ព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ២ .-

ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការនូវ គំរូ ទម្រង់ និងបែបបទស្នើសុំវិញ្ញាបនបត្រសុខភាពសម្រាប់បញ្ជាក់គុណភាពផល ផលិតផលជលផល តាមតម្រូវការប្រទេសនាំចូល ដូចភ្ជាប់ជាមួយឧបសម្ព័ន្ធនៃប្រកាសនេះ។

រាល់ការនាំចូលផល ផលិតផលជលផល រដ្ឋបាលជលផលមានភារកិច្ចត្រួតពិនិត្យលើវិញ្ញាបនបត្រសុខភាពដែលចេញដោយប្រទេសនាំចេញ។

### ប្រការ ៣ .-

នីតិវិធីនិងបែបបទស្នើសុំវិញ្ញាបនបត្រសុខភាពសម្រាប់ការនាំចេញ-នាំចូលផលផលិតផលជលផលត្រូវកំណត់ដោយប្រកាសដោយឡែក។

### ប្រការ ៤ .-

សោហ៊ុយចំណាយលើការយកគំរូសំណាកមកវិភាគនិងថ្លៃវិភាគរបស់មន្ទីរពិសោធន៍ ជាបន្ទុករបស់សាមីអ្នកស្នើសុំ។

រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវមានកាតព្វកិច្ចបង់ថ្លៃសេវាសាធារណៈជូនរដ្ឋ តាមខ្លឹមសារនៃប្រកាសរួមលេខ ១០១៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រការ ៥ .-

ប្រកាសឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៦ .-

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ [illegible] ឆ្នាំ២០១៤

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បណ្ឌិត អ៊ុក រ៉ាប៊ុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

រដ្ឋបាលជលផល
Fisheries Administration
នាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព
Department of Fisheries Post-Harvest Technologies and Quality Control
No. 186 Preah Norodom Blvd., P. O. Box 582, Phnom Penh, Cambodia
Tel/Fax: (855)-23 224 800

# វិញ្ញាបនបត្រសុខភាព
# HEALTH CERTIFICATE

វិញ្ញាបនបត្រសុខភាពនេះត្រូវបានបញ្ជាក់ក្នុងគោលបំណងនាំចេញសម្រាប់ផលិតផលជលផលដូចខាងក្រោម:
This health certificate is issued in the purpose of export for the fishery products as follows:

| | |
|---|---|
| ផលជលផលរស់ ☐<br>**Live Fishery Products** | ផលិតផលជលផលស្រស់និងកែច្នៃ ☐<br>**Fresh and Processed Fishery Products** |
| ១. រដ្ឋបាលជលផល<br>**1. Competent Authority (FISHERIES ADMINISTRATION)** | ២. លេខសំគាល់វិញ្ញាបនបត្រ<br>**2. CERTIFICATE REFERENCE NUMBER** |
| | |
| ៣. អ្នកផ្ញើ (ឈ្មោះ អាស័យដ្ឋាន លេខទូរស័ព្ទនិងអ៊ីម៉េល)<br>**3. CONSIGNOR *(name, full address with telephone and e-mail)*** | ៤. អ្នកទទួលបញ្ញើ (ឈ្មោះ អាស័យដ្ឋាន លេខទូរស័ព្ទនិងអ៊ីម៉េល)<br>**4. CONSIGNEE *(name, full address with telephone and e-mail)*** |
| | |
| ៥. ប្រទេសនាំចេញ<br>**5. COUNTRY OF EXPORT** | ៦. ប្រទេសជាគោលដៅ<br>**6. COUNTRY OF DESTINATION** |
| | |
| ៧. ច្រកចេញ<br>**7. EXIT POINT/S** | ៨. ច្រកចូល<br>**8. ENTRY POINT/S** |
| | |
| ៩. មធ្យោបាយដឹកជញ្ជូន<br>**9. MEANS OF TRANSPORT** | ១០. កាលបរិច្ឆេទចេញដំណើរ<br>**10. DATE OF DEPARTURE** |
| យន្តហោះ☐ Airplane   នាវា☐ Ship   រថភ្លើង☐ Train   យានយន្ត☐ Road vehicle   ផ្សេងទៀត☐ Other | |
| ១១. ភិនភាគនៃទំនិញ<br>**11. IDENTIFICATION OF COMMODITIES** | ១២.សីតុណ្ហភាពរបស់ផលិតផល<br>**12. TEMPERATURE OF PRODUCTS** |
| ប្រភេទ: Type: ត្រី☐ Fish   សិប្បីសត្វ☐ Mollusk   មណ្តុកសត្វ☐ Amphibian   សត្វវល្លជាតិ☐ Crustacean   ផ្សេងទៀត☐ Other | បរិយាកាស☐ Ambient   ត្រជាក់☐ Chilled   បង្កក☐ Frozen |
| ១៣. ប្រភពនៃផលិតផល<br>**13. SOURCE OF PRODUCTS** | ១៤. ទីតាំងដើមកំណើត<br>**14. PLACE OF ORIGIN** |
| ពីធម្មជាតិ☐ Wild   ការចិញ្ចឹម☐ Culture | |

១៥. ការពណ៌នាអំពីមុខទំនិញ
**15. DESCRIPTION OF COMMODITIES**

| ល.រ<br>No. | ប្រភេទ<br>*Species* | ចំនួនកញ្ចប់<br>*No. of packages* | ទម្ងន់សុទ្ធ<br>*Net weight (Kg)* | ទម្ងន់សរុប<br>*Total weight(Kg)* |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | បរិមាណសរុប (គ.ក្រ)<br>TOTAL QUANTITY (Kg) | | | |

| ១៦. ប្រភេទនៃការវេចខ្ចប់<br>16. TYPE OF PACKAGING | ១៧. ចំនួនសរុបនៃកញ្ចប់<br>17. TOTAL NUMBER OF PACKAGES | ១៨. លេខកុងតឺន័រ<br>18. CONTAINER NUMBER (S) | ១៩. លេខតែម<br>19. SEAL NUMBER (S) |
|---|---|---|---|
| | | | |

២០. ទំនិញនេះត្រូវបានចេញវិញ្ញាបនបត្រសម្រាប់
**20. COMMODITIES CERTIFIED FOR**

អាហាររបស់មនុស្ស ☐ Human consumption
វារីសត្វលម្អ ☐ Ornamental aquatic animal
ការស្រាវជ្រាវ និង/ឬ ការស៊ើបអង្កេត☐ Research and/or investigation
ផ្សេងទៀត☐ Others

២១. ការបញ្ជាក់ពីរដ្ឋបាលជលផល
**21. ATTESTATION BY THE COMPETENT AUTHORITY (FISHERIES ADMINISTRATION)**

២២. សុពលភាពរបស់វិញ្ញាបនបត្រ
**22. VALIDATY OF THE CERTIFICATE**

២៣. ចេញដោយរដ្ឋបាលជលផល
**23. ISSUED BY THE COMPETENT AUTHORITY (FISHERIES ADMINISTRATION)**

បញ្ជាក់ដោយភ្នាក់ងារត្រួតពិនិត្យផ្លូវការ
**CERTIFIED BY OFFICIAL INSPECTOR**

| | |
|---|---|
| ប្រធាននាយកដ្ឋានបច្ចេកវិទ្យាកែច្នៃនិងគុណភាព<br>Director of the Department of Fisheries Post-Harvest Technologies and Quality Control<br>.....................................<br>(Head of Safety and Quality Control) | រាជធានីភ្នំពេញ, ថ្ងៃទី.................ខែ..................ឆ្នាំ២០១...<br>Phnom Penh, Day Month Year 201.. |

បានឃើញនិងឯកភាពដោយប្រធានរដ្ឋបាលជលផល
**SEEN AND APPROVED BY THE HEAD OF THE CENTRAL FISHERIES ADMINISTRATION**

| | |
|---|---|
| ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល<br>Delegate of the Royal Government of Cambodia, Director General of Fisheries Administration<br>.....................................<br>(Head of Central Fisheries Administration) | រាជធានីភ្នំពេញ, ថ្ងៃទី.................ខែ..................ឆ្នាំ២០១...<br>Phnom Penh, Day Month Year 201... |